# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៩...សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំសន្និសីទអាស៊ាន អំពីកិច្ចការមុខងារសាធារណៈ លើកទី១៣

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិទាំង៦ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកជំនាញ
- តាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការរៀបចំសន្និសីទអាស៊ានអំពីកិច្ចការមុខងារសាធារណៈ លើកទី១៣ (សន្និសីទត្រៀម និងសន្និសីទពេញអង្គ) ដែលមានសមាសភាពដូចខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. | ឯកឧត្តម | **សេខ ឈឹមនៅ** | រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣. | ឯកឧត្តម | **ពេជ្រ ប៊ុនធិន** | រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការជាតិ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកមុខងារ សាធារណៈ | អនុប្រធាន |

| | | | | | |
|---|---|---|---|---|---|
| ៤. | ឯកឧត្តម | អ៊ុក | រ៉ាប៊ុន | រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. | ឯកឧត្តម | ញ៉ាំ | សុខា | រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៦. | ឯកឧត្តម | ឃឹម | សារិទ្ធ | រដ្ឋលេខាធិការ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧. | ឯកឧត្តម | អ៊ុក | ចាយ | រដ្ឋលេខាធិការ នៃក្រសួងផែនការ និងជាសមាជិកគណៈកម្មាធិការជាតិ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកមុខងារសាធារណៈ | សមាជិក |
| ៨. | ឯកឧត្តម | ហង្ស | ធាំធាន | អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល និងជាសមាជិកគណៈកម្មាធិការជាតិ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកមុខងារសាធារណៈ | សមាជិក |
| ៩. | លោកជំទាវ | ស៊ើង | រដ្ឋចារី | អគ្គនាយក នៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង ជាអនុប្រធានគណៈ-កម្មាធិការជាតិ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកមុខងារសាធារណៈ | សមាជិក |
| ១០. | ឯកឧត្តម | សក់ | សេដ្ឋា | អគ្គនាយករដ្ឋបាល នៃក្រសួងមហាផ្ទៃ និងជាសមាជិក គណៈ-កម្មាធិការជាតិ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកមុខងារសាធារណៈ | សមាជិក |
| ១១. | ឯកឧត្តម | ឆេព | ដារ៉ុង | អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល | សមាជិក |
| ១២. | ឯកឧត្តម | ប៊ួន | លីមហេង | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី-ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣. | ឯកឧត្តម | គឹម | គុណវឌ្ឍន៍ | អគ្គនាយក នៃក្រសួងពត៌មាន | សមាជិក |
| ១៤. | ឯកឧត្តម | ម៉ាន់ | ផល | អគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងការបរទេស និងសហ-ប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៥. | លោក | ម៉ុម | សារិន | អភិបាលរង រាជធានីភ្នំពេញ | សមាជិក |
| ១៦. | លោក | គង | ម៉ារ៉ុង | អភិបាលរងទី ១ ខេត្តកំពង់ស្ពឺ | សមាជិក |

**ប្រការ២** : គណៈកម្មការមានភារកិច្ចដឹកនាំ និងសំរេច លើដំណើរការទូទៅនៃសន្និសីទដោយសហការជាមួយអគ្គលេខាធិការដ្ឋានអាស៊ានកម្ពុជា និងលេខាធិការដ្ឋានអាស៊ាន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ អោយទទួលបានលទ្ធផលល្អ ។

**ប្រការ៣** : គណៈកម្មការមានសិទ្ធិចាត់តាំងអនុគណៈកម្មការមួយចំនួន តាមការចាំបាច់ជាជំនួយការ គឺ ÷

១- **អនុគណៈកម្មការពិធីការ** : មានភារកិច្ចធ្វើបដិសណ្ឋារកិច្ចទទួលជូនគណៈប្រតិភូ រៀបចំអង្គសន្និសីទ រួមមាន ពិធីបើក-បិទ ដំណើរការប្រជុំ ពិធីចុះហត្ថលេខា ទង់ជាតិតូច-ធំ នៃប្រទេសជាសមាជិកអាស៊ាន ផ្កាកគណៈប្រតិភូ ពិធីជប់លៀង សិល្បៈ វត្ថុអនុស្សាវរីយ៍ និងបែបបទដទៃទៀត នៃពិធីការសំរាប់កិច្ចប្រជុំជំនាញថ្នាក់រដ្ឋមន្ត្រី ។

២- **អនុគណៈកម្មការពត៌មាន** : មានភារកិច្ចធ្វើសេចក្តីជូនដំណឹងចំពោះសាធារណៈមតិជាតិ-អន្តរជាតិ រៀបចំបដា ប័ណ្ណប្រកាស និងពាក្យស្លោកស្វាគមន៍ ផ្លាករថយន្ត ប័ណ្ណចូលរួម ចុះឈ្មោះភ្ញៀវជាតិ-អន្តរជាតិ ចែកចាយ ឯកសារ ថតរូបភាព អញ្ជើញប្រព័ន្ធផ្សព្វផ្សាយ និងសំរបសំរួលរាល់ការងារ ពាក់ព័ន្ធនឹងពត៌មាន ។

៣- **អនុគណៈកម្មការឯកសារ** : មានភារកិច្ចរៀបចំបកប្រែ ចែកចាយគ្រប់ឯកសារពាក់ព័ន្ធនឹងដំណើរការសន្និសីទ មានជាអាទិ៍ កម្មវិធីនៃសន្និសីទត្រៀម និងពេញអង្គ សុន្ទរកថាស្វាគមន៍-បើក-បិទ របាយការណ៍សំរេច កំណត់ហេតុនៃអង្គសន្និសីទ ....។

៤- **អនុគណៈកម្មការផ្គត់ផ្គង់** : មានភារកិច្ចដោះស្រាយថវិកាតាមការសំរេចរបស់ប្រធានគណៈកម្មការរៀបចំសន្និសីទ និងចាត់ចែងទូទាត់បិទបញ្ជី ។

៥- **អនុគណៈកម្មការសន្តិសុខ** : មានភារកិច្ចការពារសន្តិសុខជូនគណៈប្រតិភូ និងអង្គសន្និសីទទាំងមូលនៅគ្រប់ ទីកន្លែងស្របតាមកម្មវិធី ក្នុងន័យអោយសន្និសីទប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាពល្អ ។

៦- **លេខាធិការដ្ឋានសន្និសីទ** : ជាសេនាធិការរបស់គណៈកម្មការ មានភារកិច្ចប្រចាំការ សំរបសំរួលបកប្រែ និងចាត់តាំង រាល់កម្មវិធី នៃសន្និសីទជាមួយគ្រប់អនុគណៈកម្មការ រាយការណ៍ពីសំណូមពរ និងបញ្ហាសុខភាពរបស់គណៈប្រតិភូ ។

៧- **ក្រុមកុំព្យូទ័រ** : មានភារកិច្ចវាយគ្រប់ឯកសារ នៃសន្និសីទ និងសំរបសំរួលរាល់ទំនាក់ទំនងអេឡិចត្រូនិច ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ក្រសួងស្ថាប័នពាក់ព័ន្ធ និង សមាសភាពដូចមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ